# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**

# សារលិខិតជូនពរ

## សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា និងជាប្រធានកិត្តិយសគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ

- **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជាទីគោរពដ៏ខ្ពង់ខ្ពស់ !

ក្នុងឱកាសជ័យមង្គល អាយុវឌ្ឍនាគម្រប់ ៦១ឆ្នាំ ឈានចូល ៦២ឆ្នាំ របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ដ៏ប្រសើរថ្លៃថ្លានេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងក្នុងនាមខ្ញុំ និងភរិយាខ្ញុំ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ សូមសម្តែងនូវការគោរពប្រកបដោយកតញ្ញូវេទិតាធម៌ និងការកោតសរសើរយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ក្នុងកាតព្វកិច្ចនិងភារកិច្ចដ៏ឧត្តុង្គឧត្តមដែល**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បាននឹងកំពុងបំពេញដ៏មមារញឹកក្នុងការបម្រើប្រទេសជាតិមាតុភូមិ និងប្រជាជន ក្នុងគោលបំណងមនុស្សធម៌ ដោយមិនរើសអើងនិន្នាការនយោបាយ ប្រកាន់ពណ៌សម្បុរ ជំនឿ សាសនានោះឡើយ។ គំរូវីរភាពរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បានចារឹកទុកក្នុងប្រវត្តិសាស្ត្រនៃវីរៈអ្នកដឹកនាំស្ត្រីកម្ពុជា ហើយក៏ជានិមិត្តរូបភរិយាដ៏ប្រពៃថ្លៃថ្លា ជាអ្នកម្តាយប្រកបដោយព្រហ្មវិហារធម៌ និងសប្បុរសធម៌ ហើយ**សម្តេច** ថែមទាំងបានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលយ៉ាងសកម្មផុលផុស ដើម្បីជួយដល់សកម្មភាពមនុស្សធម៌នានា ពោលគឺ " **ទីណាមានទុក្ខលំបាក ទីនោះមានសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** " ទន្ទឹមនឹងនេះ **សម្តេច** ថែមទាំងជម្រុញលើកតម្កើងស្មារតីមនុស្សធម៌ជាសកល និងលើកស្ទួយតម្លៃស្ត្រីខ្មែររហូតទទួលបានកិត្យានុភាព មោទនភាពជាតិលើឆាកអន្តរជាតិជាបន្តបន្ទាប់។

នាឱកាសដ៏វិសេសវិសាលថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមប្រសិទ្ធពរជ័យ សិរីមង្គលវិបុលសុខ មហាប្រសើរគ្រប់ប្រការ ជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និងសូមបួងសួងគុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តសិទ្ធក្នុងលោក តាមជួយបីបាច់ថែរក្សា **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បានប្រកបដោយសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួន ក្លៀវក្លា បញ្ញាញាណវាងវៃ អាយុយឺនយូរ ដើម្បីបន្តដឹកនាំស្ថាប័នកាកបាទក្រហមកម្ពុជា ឲ្យបានរីកចម្រើនថ្កុំថ្កើងរុងរឿងជានិរន្តរ៍តរៀងទៅ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និង **សម្តេចអគ្គមហាសេនាបតីតេជោ** ព្រមទាំង បុត្រា បុត្រី បុត្រប្រសា ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមជួបតែនឹងពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែ...ធ្នូ.....ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**

វិថីហ្សកឌឺមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៨ អ៊ីមែល៖ generalsec@mod.gov.kh